**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ...០០២... សហវ.ខ៣៥

# សេចក្តីជូនដំណឹង

## ស្តីពីកាតព្វកិច្ចបង់ពន្ធប៉ាតង់

អនុលោមតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ សហគ្រាស-ក្រុមហ៊ុន ដែលជាអ្នកជាប់ពន្ធតាមរបបម៉ៅការនិងរបបស្វ័យប្រកាសឱ្យបានជ្រាបអំពីកាតព្វកិច្ចបង់ពន្ធប៉ាតង់ដូចខាងក្រោមនេះ :

១- ពន្ធប៉ាតង់ជាពន្ធកំណត់លើផលរបរសរុបប្រចាំឆ្នាំ ដែលត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ ។ សម្រាប់សហគ្រាស-ក្រុមហ៊ុន ដែលទើបចាប់ផ្តើមប្រកបអាជីវកម្មត្រូវបង់ពន្ធប៉ាតង់ពេញមួយឆ្នាំប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល ៦ខែ ដើមឆ្នាំ ឬបង់ពន្ធប៉ាតង់ពាក់កណ្តាលឆ្នាំប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល ៦ខែ ចុងឆ្នាំ ។ សហគ្រាស-ក្រុមហ៊ុន ដែលមានសាខា-ឃ្លាំង-រោងចក្រ-រោងជាង សម្រាប់មុខរបរអាជីវកម្មតែមួយ នៅក្នុងខេត្ត/ក្រុងតែមួយ មិនចាំបាច់បង់ពន្ធប៉ាតង់ផ្សេងគ្នាទេ ប៉ុន្តែបើមានមុខរបរអាជីវកម្មខុសៗគ្នា ឬស្ថិតនៅក្នុងខេត្ត/ក្រុងផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ទៅតាមមុខរបរនីមួយៗ និងទៅតាមខេត្ត/ក្រុងដោយឡែកៗពីគ្នា ។

២- កម្រិតប្រាក់ពន្ធប៉ាតង់ដែលត្រូវបង់មានដូចខាងក្រោមនេះ :

ក- សម្រាប់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបម៉ៅការ ពន្ធប៉ាតង់ត្រូវបានកំណត់លើផលរបរប៉ាន់ស្មានសរុបក្នុងឆ្នាំចំពោះអ្នកជាប់ពន្ធដែលទើបប្រកបអាជីវកម្មថ្មី និងកំណត់លើផលរបរសរុបពីឆ្នាំកន្លងទៅចំពោះអ្នកជាប់ពន្ធចាស់ ។ កម្រិតអតិបរមានៃប្រាក់ពន្ធប៉ាតង់ប្រចាំឆ្នាំត្រូវបង់មានចំនួន ១.១៤០.០០០ រៀល ។

ខ- សម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ការចុះបញ្ជីដំបូងត្រូវធ្វើឡើងក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយមានសកម្មភាពសេដ្ឋកិច្ចឬក្រោយកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម ហើយត្រូវមានកាតព្វកិច្ចបង់ :

| | |
|---|---|
| - ថ្លៃឯកសារចុះបញ្ជីរួមទាំងសាលាកបត្រព័ត៌មាន : | ៥.០០០ រៀល |
| - បង់ពន្ធប្រថាប់ត្រា : | ១០០.០០០ រៀល |
| - ពន្ធប៉ាតង់ប្រចាំឆ្នាំ : | ១.១៤០.០០០ រៀល |
| - ថ្លៃប័ណ្ណប៉ាតង់ : | ១.០០០ រៀល |
| - ថ្លៃវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម : | ១.០០០ រៀល |
| សរុប | ១.២៤៧.០០០ រៀល |

ដោយឡែកចំពោះអ្នកជាប់ពន្ធចាស់ត្រូវបង់តែពន្ធប៉ាតង់និងថ្លៃប័ណ្ណប៉ាតង់តែប៉ុណ្ណោះ ។

៣- អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចបង់តែទឹកប្រាក់ដូចបានជម្រាបជូនខាងលើ ឱ្យបានត្រឹមត្រូវទៅតាមពេលវេលាដែលបានកំណត់ ។ ក្នុងករណីមិនបានបង់ឬព្យាយាមគេចវេសពីការបង់ប្រាក់ពន្ធប៉ាតង់នឹងត្រូវទទួលរងនូវទោសទណ្ឌដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ។ អ្នកជាប់ពន្ធត្រូវដាក់តាំងឬព្យួរប័ណ្ណប៉ាតង់នៅទីកន្លែងប្រកបអាជីវកម្មជាគោលដើមរបស់ខ្លួន ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់ថា លោក/លោកស្រីជាម្ចាស់សហគ្រាស-ក្រុមហ៊ុន ដែលជាអ្នកជាប់ពន្ធតាមរបបម៉ៅការនិងរបបស្វ័យប្រកាស ពិតជាយកចិត្តទុកដាក់អនុវត្តតាមសេចក្តីជូនដំណឹងនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០៧

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798